# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រកាសថ្កោលទោសទង្វើក្បត់ជាតិរបស់ទណ្ឌិត សម រង្ស៊ី និងគាំទ្រចំណាត់ការតាមផ្លូវច្បាប់ លើជនក្បត់ជាតិរូបនេះ

ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសម្តែងការខឹងសម្បា និងថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើក្បត់ជាតិ ក្បត់ទឹកដីរបស់ទណ្ឌិត សម រង្ស៊ី។ ក្នុងញត្តិថ្កោលទោសចំពោះទង្វើក្បត់ជាតិនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានគូសបញ្ជាក់ថា «ទង្វើរបស់ទណ្ឌិត គឺជាទង្វើក្បត់ជាតិ និងប្រជាជនកម្ពុជា ផ្ទុយស្រឡះពីច្បាប់រដ្ឋធម្មនុញ្ញ»។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា «បងប្អូនយើងប្រឆាំងដាច់ខាតចំពោះទណ្ឌិត សម រង្ស៊ី អ្នកនយោបាយបញ្ច្រាស់ទិស ដែលបានចុះហត្ថលេខាកាត់ដី៤ខេត្ត (ស្ទឹងត្រែង រតនគិរី មណ្ឌលគីរី ក្រចេះ ) ឲ្យចលនាជនជាតិដើមភាគតិចវៀតណាម ម៉ុងតាញ៉ា បើខ្លួនបានឈ្នះឆ្នោតកាន់រដ្ឋាភិបាល ដែលនេះគឺជាអំពើក្បត់ជាតិ ក្បត់ប្រជាជនយ៉ាងជាក់ស្តែងមិនអាចប្រកែកបាន ដែលពួកយើងខ្ញុំ មិនអាចនៅស្ងៀមបានឡើយ។ ទង្វើនេះ គឺជាទង្វើដ៏កខ្វក់ក្បត់ជាតិ ក្បត់ទឹកដី ក្បត់ប្រជាជនខ្មែរ ក្បត់ដែនអធិបតេយ្យជាតិ ដែលប្រជាជនខ្មែរមិនអាចលើកលែងឲ្យបាននោះឡើយ។ យើងខ្ញុំ ទាំងអស់គ្នាសូមប្រឆាំងដាច់ខាត និងមិនអាចអត់ឱនឲ្យបាននោះឡើយ»។

ទន្ទឹមនឹងការបង្ហាញការខឹងសម្បា និងថ្កោលទោសហើយនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ព្រមទាំង ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏បានប្រកាសគាំទ្រ ព្រមទាំងអំពាវនាវដល់រាជរដ្ឋាភិបាល ឲ្យចាត់វិធានការតាមផ្លូវច្បាប់ដ៏ម៉ឺងម៉ាត់បំផុតមិនអាចអត់ឱនឲ្យ ទណ្ឌិត សម រង្ស៊ី នោះឡើយ។ «សូមគាំទ្រយ៉ាងពេញទំហឹងឲ្យរាជរដ្ឋាភិបាលចាត់វិធានការ ផ្លូវច្បាប់ចំពោះទណ្ឌិត សម រង្ស៊ី ដោយគ្មានការលើកលែងនោះឡើយ»។

លោក សម រង្ស៊ី កាលពីឆ្នាំ២០១៣ បានធ្វើកិច្ចព្រមព្រៀងបែងចែកទឹកដីចំនួន៤ខេត្តទៅ លោក Kok Ksor (កុក សរ) មេដឹកនាំវៀតណាមជនជាតិភាគតិច Degar (ដេកា) ឬម៉ុងតាញ៉ា (វៀតណាមសេរី) នៅពេលដែលរូបលោកឈ្នះឆ្នោតដឹកនាំរាជរដ្ឋាភិបាលកម្ពុជា។

**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសម្ពោធស្ពានកោះប៉ែននៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ បានថ្លែងថា ការចុះកិច្ចព្រមព្រៀងរវាងទណ្ឌិត សម រង្ស៊ី ជាមួយមេដឹកនាំជនជាតិភាគតិចវៀតណាម កុក សរ គឺជាទង្វើក្បត់ជាតិដ៏ធ្ងន់ធ្ងរ។ សម្តេចតេជោបានបញ្ជាឲ្យក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃពិនិត្យលើបញ្ហានេះ ហើយត្រូវចាត់វិធានការទៅតាមផ្លូវច្បាប់។

កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានដាក់ពាក្យបណ្តឹងទៅតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីប្តឹងទណ្ឌិត សម រង្ស៊ី ក្រោមការចោទប្រកាន់ពីបទ «ក្បត់ជាតិ» ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងសម្ងាត់កាត់ទឹកដីកម្ពុជា ទៅឱ្យជនជាតិភាគតិចវៀតណាមម៉ុងតាញ៉ាផងដែរ។

អគ្គស្នងការដ្ឋាននគរបាលជាតិ បានចាត់ទុកថា វីដេអូសកម្មភាព និងទង្វើដែលចុះហត្ថលេខាប្រគល់ឱ្យរដ្ឋបរទេសនូវដែនដី ដែលធ្វើឡើងដោយទណ្ឌិត សម រង្ស៊ី គឺជាអំពើក្បត់ជាតិយ៉ាងពិតប្រាកដ។ ដូច្នេះស្នើឱ្យតំណាងអយ្យការ ទទួលចាត់ការចំពោះអំពើក្បត់ជាតិឃុបឃិតកាត់ទឹកដីឱ្យជនបរទេសរវាងឈ្មោះ សម រង្ស៊ី និងបរទេស ប៉ះពាល់ដល់អធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដើម្បីផ្តន្ទាទោសតាមច្បាប់។